**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ ៦៥០/០៧ គ.ជ.ប**

# សេចក្តីណែនាំ
## ស្តីពី
## ការបន្តអាណត្តិរបស់គណៈកម្មាធិការចំពោះកិច្ចពហុបក្សនៅក្នុងដំណាក់កាល ធ្វើបច្ចុប្បន្នភាពនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

យោងតាមសេចក្តីណែនាំលេខ ៦១០/០៧ គ.ជ.ប ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៧ និងតាមស្មារតីអង្គប្រជុំ គ.ជ.ប ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៧ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមណែនាំ និងជូនដំណឹងដល់លោក លោកស្រីប្រធានលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត (លខ/កប) ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ/ស) និង គណបក្សនយោបាយទាំងអស់ ដូចខាងក្រោម ៖

- គណៈកម្មាធិការចំពោះកិច្ចពហុបក្ស ត្រូវបានបន្តអាណត្តិរហូតដល់**ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៧** ដើម្បីអនុវត្តកិច្ចការរបស់ខ្លួននៅក្នុងដំណាក់កាលធ្វើបច្ចុប្បន្នភាពនៃការពិនិត្យបញ្ជីឈ្មោះ និង ចុះឈ្មោះបោះឆ្នោត ។
- លខ/កប និង កបឃ/ស ទាំងអស់ ត្រូវយកចិត្តទុកដាក់សហការជាមួយគណៈកម្មាធិការចំពោះកិច្ចពហុបក្សក្នុងអាណត្តិបន្តនេះ និង អ្នកសង្កេតការណ៍បោះឆ្នោតជាតិ អន្តរជាតិ ដែលចូលរួមក្នុងដំណើរការសម្អាតបញ្ជីបោះឆ្នោតឱ្យបានល្អប្រសើរ ។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រីប្រធាន លខ/កប និង កបឃ/ស យកចិត្តទុកដាក់អនុវត្តឱ្យមានប្រសិទ្ធភាព ។/

ភ្នំពេញ ថ្ងៃទី១៩ ខែ តុលា ឆ្នាំ ២០០៧
**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ប្រធាន**

អ៊ឹម_សួស្តី

**ចម្លងជូន**
- ក្រសួងមហាផ្ទៃ
- អភិបាលខេត្ត ក្រុង ស្រុកខ័ណ្ឌ
- គណបក្សនយោបាយ
  "ដើម្បីរួមសហការ"
- ឯកសារ កាលប្បវត្តិ